ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១០១៩ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២

# ប្រកាស
## ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិថ្នែក្នុងជំពូក តាមគណនីនិងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- តាមការចាំបាច់ដើម្បីអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

<u>**សម្រេច**</u>

**ប្រការ១.-** ឥណទានចំណាយថវិកាថ្នាក់ជាតិ ដូចមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ហើយដែលត្រូវបានបែងចែកតាមជំពូកដោយអនុក្រឹត្យស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ដូចបានយោងខាងលើ ត្រូវបានបែងចែកលម្អិតតាមគណនីនិងអនុគណនី ដូចមានចែងក្នុងសៀវភៅថវិកា ដែលភ្ជាប់នឹងប្រកាសនេះ។

**ប្រការ២.-** រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន ដែលជាអាណាប័កដើមខ្សែត្រូវរៀបចំប្រកាសស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិនិងការផ្ទេរឥណទាន ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្នុងការគ្រប់គ្រងឥណទានថវិកានៃមន្ទីរជំនាញរបស់ខ្លួននៅតាមរាជធានី ខេត្ត ឲ្យបានទាន់ពេលវេលាទៅតាមប្រកាសគំរូ ដូចមានភ្ជាប់នឹងប្រកាសនេះ។

**ប្រការ៣.-** រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលនៃគណៈអភិបាលគ្រប់រាជធានី ខេត្ត ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ។

**ប្រការ៤.-** ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់រាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ